**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..២០១៨៨.៩...អពដ

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ១០រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១
ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបង្ហាញខ្លួន ស្តែនម្រាមដៃ និងថតរូបបេក្ខជនដែលបានដាក់ពាក្យស្នើសុំប្រឡងប្រជែង ចូលបម្រើការងារជាមន្ត្រីរាជការជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន ៨០ រូប (តាមរយៈ Online) នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជូនដំណឹងដល់លោក លោកស្រី អ្នកនាង កញ្ញា ជានិស្សិត មន្ត្រីរាជការ ឬសាធារណជនទូទៅដែលបានដាក់ពាក្យស្នើសុំប្រឡងប្រជែងចូលបម្រើការងារជាមន្ត្រីរាជការជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន ៨០ រូប (តាមរយៈ Online) ឱ្យបានជ្រាបថា លោក លោកស្រីត្រូវមកបង្ហាញខ្លួន ស្តែនម្រាមដៃ និងថតរូប នៅ**សាលាជាតិពន្ធដារ** តាមកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដូចខាងក្រោម÷

- កាលបរិច្ឆេទ : ចាប់ពីថ្ងៃទី**១៨** ដល់ថ្ងៃ**២៦** ខែធ្នូ ឆ្នាំ២០១៧ (ឈប់សម្រាកនៅថ្ងៃសៅរ៍ និងអាទិត្យ)
- ពេលវេលា : ពេលព្រឹក ចាប់ពីម៉ោង **០៨:៣០**នាទី ដល់ **១១:៣០**នាទី និង
  ពេលរសៀល ចាប់ពីម៉ោង **១៤:៣០**នាទី ដល់ **១៧:០០**នាទី។

**បញ្ជាក់:** លោក លោកស្រី អ្នកនាង កញ្ញា ត្រូវយកមកជាមួយនូវបង្កាន់ដៃដែលបានបោះពុម្ពចេញពីប្រព័ន្ធចុះឈ្មោះតាមរយៈ Online ព្រមជាមួយ÷

១- សញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬសញ្ញាបត្រសមមូលមានតម្លៃស្មើ ***(បានយកទៅបញ្ជាក់ត្រឹមត្រូវ)***
២- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ***(បានយកទៅបញ្ជាក់ត្រឹមត្រូវ)***
៣- សំបុត្រកំណើត ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតបញ្ជាក់ទីលំនៅ ***(បានយកទៅបញ្ជាក់ត្រឹមត្រូវ)***
៤- លិខិតបញ្ជាក់បទពិសោធន៍ការងារ ឬ សៀវភៅការងារ ឬ វិញ្ញាបនបត្របញ្ជាក់រដ្ឋបាល ឬ កិច្ចសន្យាការងារ ឬ លិខិតបញ្ជាក់ពីស្ថានភាពការងារ ឬ ប្រកាសស្តីពីការទទួលស្គាល់ក្របខ័ណ្ឌ (សម្រាប់មន្ត្រីក្របខ័ណ្ឌ) ដែលមានបញ្ជាក់ចំនួនឆ្នាំនៃការបំពេញការងារ ***(អាចថតចម្លងស-ខ្មៅ)***

ក្នុងករណីលោក លោកស្រីអ្នកនាង កញ្ញា ខកខានពុំបានមកបង្ហាញខ្លួន ស្តែនម្រាមដៃ និងថតរូបតាមការកំណត់របស់អគ្គនាយកដ្ឋានពន្ធដារ មានន័យថាលោក លោកស្រី អ្នកនាង កញ្ញា បានបោះបង់សិទ្ធិក្នុងការប្រឡងប្រជែងនេះដោយស្ម័គ្រចិត្ត។

អាស្រ័យហេតុនេះ សូមលោក លោកស្រី អ្នកនាង កញ្ញា ជានិស្សិត មន្ត្រីរាជការ និងសាធារណជនទូទៅ ដែលបានចុះឈ្មោះស្នើសុំប្រឡងប្រជែងចូលបម្រើការងារជាមន្ត្រីរាជការជំនាញបច្ចេកវិទ្យាព័ត៌មាន (តាម Online) រួចហើយ អញ្ជើញមកបង្ហាញខ្លួន ស្តែនម្រាមដៃ និងថតរូបតាមពេលវេលា និងទីកន្លែង ដែលបានកំណត់កុំបីខាន។

អាសយដ្ឋានសាលាជាតិពន្ធដារ÷ អគារលេខ៤១-៤៣ ផ្លូវលេខ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)។

**អគ្គនាយកដ្ឋានពន្ធដារ**